**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**រាជបណ្ឌិត្យសភាកម្ពុជា**

Royal Academy of Cambodia
Académie Royale du Cambodge

**គណៈកម្មាធិការលទ្ធកម្ម ( គ.លទ-PC )**

លេខៈ ០១០ /២១ ស.ជ.ណ

ថ្ងៃ ព្រហស្បតិ៍ ១៤កើត ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃសម្រាប់ការផ្គត់ផ្គង់ប្រេងឥន្ធនៈឆមាសទី១ ឆ្នាំ២០២១ របស់រាជបណ្ឌិត្យសភាកម្ពុជា

រាជបណ្ឌិត្យសភាកម្ពុជា សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា រាជបណ្ឌិត្យសភាកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈសម្រាប់ការផ្គត់ផ្គង់ប្រេងឥន្ទនៈឆមាសទី១ ឆ្នាំ២០២១។

រាជបណ្ឌិត្យសភាកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញ ដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅ អង្គភាពលទ្ធកម្ម រាជបណ្ឌិត្យសភាកម្ពុជា ដែលមានអាសយដ្ឋាននៅ មហាវិថីសហព័ន្ធរុស្សី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ (អគារF ជាន់ទី២) ចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២១ រៀងរាល់ម៉ោងធ្វើការ ( ទូរសព្ទទាក់ទងលេខៈ ០១៧ ៦៩៩ ៩៨៧ )។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ១០:០០ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២១។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅ អង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១០:០០ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២១។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយ អង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ។

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**
**និងជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា**

បណ្ឌិតសភាចារ្យ **សុខ ទូច**

**ចម្លងជូនៈ**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ « អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ»
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ-កាលប្បវត្តិ